ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពីការរៀបចំកិច្ចប្រជុំលើកទី៣ នៃក្រុមការងាររួម ស្ដីពីកិច្ចសហប្រតិបត្តិការ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងគណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី តាមរយៈប្រព័ន្ធវីដេអូ

ដោយអនុលោមតាមក្របខណ្ឌអនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងគណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី ដែលត្រូវបានចុះហត្ថលេខាដោយ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងឯកឧត្ដម **ទីហ្គ្រាន សារស៊ីយ៉ាន** (Tigran Sargsyan) ប្រធានក្រុមប្រឹក្សាភិបាលនៃគណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ នៅទីក្រុងម៉ូស្គូ សហព័ន្ធរុស្ស៊ី និងយោងតាមសេចក្ដីថ្លែងការណ៍រួមនៃកិច្ចប្រជុំលើកទី២ នៃក្រុមការងាររួមស្ដីពីកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងគណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី ដែលត្រូវបានចុះហត្ថលេខា កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ នៅទីក្រុងម៉ូស្គូ សហព័ន្ធរុស្ស៊ី ភាគីទាំងពីរបានឯកភាពគ្នាក្នុងការរៀបចំកិច្ចប្រជុំលើកទី៣ នៃក្រុមការងាររួមនេះ ដើម្បីបន្តពង្រឹងមិត្តភាព និងលើកកម្ពស់កិច្ចសហប្រតិបត្តិការទ្វេភាគីឱ្យកាន់តែល្អប្រសើរ។

កិច្ចប្រជុំនេះ នឹងត្រូវរៀបចំនៅ**<u>ថ្ងៃទី៧-៨ ខែកញ្ញា ឆ្នាំ២០២១</u>** តាមរយៈប្រព័ន្ធវីដេអូ (Virtual Conference) នៅទីស្ដីការក្រសួងពាណិជ្ជកម្ម ក្រោមអធិបតីភាពលោកជំទាវ **តឹកវ៉េត កំរង** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងជាប្រធានក្រុមការងាររួមសម្រាប់ភាគីកម្ពុជា ជាមួយនឹងសហប្រធានឯកឧត្ដម **សឺហ្គេ គ្លាហ៊ៀវ** (Sergey GLAZIEV) សមាជិកក្រុមប្រឹក្សាភិបាល រដ្ឋមន្ត្រីទទួលបន្ទុកសមាហរណកម្មនិងម៉ាក្រូសេដ្ឋកិច្ចនៃគ.ស.អ.អ សម្រាប់ភាគីគ.ស.អ.អ ដោយមានការអញ្ជើញចូលរួមពីមន្ត្រីជាន់ខ្ពស់មកពីក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ដែលជាសមាជិកនៃក្រុមការងាររួម។

គោលបំណងនៃកិច្ចប្រជុំនេះគឺ ដើម្បីពិនិត្យពិភាក្សានិងតាមដានវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការ កិច្ចព្រមព្រៀង និងអនុស្សរណៈនៃការយោគយល់គ្នា ដែលភាគីទាំងពីរសម្រេចបានកន្លងមក ព្រមទាំងស្វែងរកនូវកាលានុវត្តភាពជាសក្ដានុពលសម្រាប់បន្តលើកកម្ពស់ និងពង្រឹងកិច្ចសហប្រតិបត្តិការថ្មីៗបន្ថែមទៀតរវាងភាគីទាំងពីរ។

កិច្ចប្រជុំ នឹងពិភាក្សាអំពីកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗមួយចំនួនដូចជាៈ (១) កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មនិងវិនិយោគ (២) កិច្ចសហប្រតិបត្តិការលើវិស័យគយ (៣) វិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (៤) វិស័យទូរគមនាគមន៍ ការអភិវឌ្ឍឌីជីថល និងបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន (៥) វិស័យឧស្សាហកម្ម ថាមពល និងហេដ្ឋារចនាសម្ព័ន្ធ (៦) របាំងបច្ចេកទេសពាណិជ្ជកម្ម បទបញ្ញត្តិបច្ចេកទេស និងអនាម័យនិងភូតគាមអនាម័យ និង(៧)កម្មសិទ្ធិបញ្ញា កិច្ចការការពារអ្នកប្រើប្រាស់ និងការប្រកួតប្រជែង។

ថ្ងៃចន្ទ ១៤រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១

ក្រសួងពាណិជ្ជកម្ម

ឡូតិ៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរសព្ទ/ទូរសារៈ (៨៥៥) ២៣ ៨៦៦ ៤៦៩
Lot 19-61 Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Fax: (855) 23 866 469